# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០២៥៦ ព.ណ.ក.ប.ព.ប្រក

ក្រសួងព័ត៌មាន

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការគ្រប់គ្រងការចុះបញ្ជីពាណិជ្ជកម្ម និងកិច្ចការពារម៉ាក និងពាណិជ្ជនាម សម្រាប់អាជ្ញាបណ្ណលើវិស័យព័ត៌មាន និងសោតទស្សន៍

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** **រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខនស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខនស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៤ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល សោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ របស់ក្រសួងព័ត៌មាន
- យោងតាមតម្រូវការចាំបាច់

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១** .-

ប្រកាសនេះមានគោលបំណងគ្រប់គ្រងការចុះបញ្ជីពាណិជ្ជកម្ម សម្រាប់អាជ្ញាបណ្ណលើវិស័យព័ត៌មាន និងសោតទស្សន៍ និងចុះបញ្ជីម៉ាក ពាណិជ្ជនាម តាមការស្នើសុំរបស់ប្រតិបត្តិករប្រព័ន្ធផ្សព្វផ្សាយស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២** .-

ប្រកាសនេះមានគោលដៅកំណត់ដូចខាងក្រោម៖

១. ចុះបញ្ជីពាណិជ្ជកម្ម ការពារម៉ាក និងពាណិជ្ជនាម លើវិស័យព័ត៌មាន និងសោតទស្សន៍ ដើម្បីធានាថាអត្តសញ្ញាណនៃ អង្គភាព ស្ថាប័នសារព័ត៌មាន និងសោតទស្សន៍នីមួយៗ មិនជាន់លើអត្តសញ្ញាណនៃអង្គភាព ស្ថាប័នព័ត៌មាន និងសោតទស្សន៍ដទៃទៀត ដែលបានច្បាប់អនុញ្ញាតរួចហើយ។

២. ការពារផលប្រយោជន៍ស្របច្បាប់របស់អ្នកស្នើសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងបញ្ជីម៉ាក ដើម្បីការពារការប្រកួតប្រជែងមិនស្មោះត្រង់។

៣. មិនអនុញ្ញាតឲ្យប្រើប្រាស់ម៉ាក និងពាណិជ្ជនាម ដែលបណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ជាសាធារណៈ សីលធម៌សង្គម ឬប្រពៃណីល្អរបស់ជាតិ និងម៉ាកដែលមិនអាចចុះបញ្ជីបាន ដូចមានកំណត់ក្នុងច្បាប់ជាធរមាន។

**ប្រការ៣** .-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយដែលធ្វើអាជីវកម្ម ឬសេវាកម្មលើវិស័យព័ត៌មាន និងសោតទស្សន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤** .-

វាក្យសព្ទដែលប្រើនៅក្នុងប្រកាសអន្តរក្រសួងនេះ ត្រូវបានកំណត់ន័យដូចខាងក្រោម៖

- អាជ្ញាបណ្ណ សំដៅដល់ប្រកាស លិខិតអនុញ្ញាត វិញ្ញាបនបត្រអនុញ្ញាតឱ្យប្រកបអាជីវកម្មលើវិស័យព័ត៌មាន និងសោតទស្សន៍។
- ប្រតិបត្តិករប្រព័ន្ធផ្សព្វផ្សាយ សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើអាជីវកម្ម ឬសេវាកម្មលើវិស័យព័ត៌មាន និងសោតទស្សន៍ ដើម្បីរកប្រាក់ចំណេញ។

- ម៉ាក សំដៅដល់សញ្ញាដែលមើលឃើញ ហើយអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ។
- ពាណិជ្ជនាម សំដៅដល់ឈ្មោះ ឬសញ្ញាសម្គាល់ ឬជាឈ្មោះ និងសញ្ញាសម្គាល់សម្រាប់បញ្ជាក់ និងសម្គាល់លក្ខណៈខុសៗគ្នានៃសហគ្រាសនីមួយៗ។
- នាមករណ៍ សំដៅដល់ឈ្មោះអង្គភាព ស្ថាប័ន ឬក្រុមហ៊ុន ដែលធ្វើពាណិជ្ជកិច្ច ឬអាជីវកម្ម លើវិស័យព័ត៌មាន និងសោតទស្សន៍។
- បញ្ជីពាណិជ្ជកម្ម សំដៅដល់ការគ្រប់គ្រង និងកាន់កាប់នូវបញ្ជីមួយចុះអត្តលេខនៃពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្ម។
- អត្តសញ្ញាណបណ្ណនៃសារព័ត៌មាន សំដៅដល់ពាណិជ្ជនាម និងម៉ាករបស់អង្គភាព ស្ថាប័នសារព័ត៌មាន។
- អាជីវកម្ម ឬសេវាកម្ម សំដៅដល់សកម្មភាពសេដ្ឋកិច្ចរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានគោលដៅទាញយកប្រាក់ចំណូលអំពីការផលិត និងលក់ផលិតផល ឬការផ្គត់ផ្គង់សេវា ឬសកម្មភាពផ្សេងៗទៀត។

## ជំពូកទី២
## ការចុះបញ្ជីពាណិជ្ជកម្មលើវិស័យព័ត៌មាន និងសោតទស្សន៍

**ប្រការ៥** .-

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពីក្រសួងព័ត៌មានក្នុងការគោលបំណងធ្វើអាជីវកម្ម ឬ សេវាកម្មលើវិស័យព័ត៌មាន និងសោតទស្សន៍ រូបវន្តបុគ្គល ឬនីតិបុគ្គល ក្នុងរយៈពេល ២ (ពីរ) សប្តាហ៍ ត្រូវចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៦** .-

ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ ក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យលើភាពត្រឹមត្រូវ នៃលក្ខខណ្ឌតម្រូវព័ត៌មាន និងឯកសារភ្ជាប់ដែលត្រូវបានបំពេញដោយអ្នកដាក់ពាក្យស្នើសុំ និងត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មតាមទម្រង់អេឡិចត្រូនិកដែលអាចបោះពុម្ពបាន តាមរយៈគេហទំព័រចុះបញ្ជីដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ជូនសាមីខ្លួន និងក្រសួងព័ត៌មាន សម្រាប់ផ្តល់អាជ្ញាបណ្ណការធ្វើអាជីវកម្ម ឬសេវាកម្មលើវិស័យព័ត៌មាន និងសោតទស្សន៍។

**ប្រការ៧** .-

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើអាជីវកម្ម ឬសេវាកម្មលើវិស័យព័ត៌មាន និងសោតទស្សន៍ ត្រូវប្រើប្រាស់នាមករណ៍ ដែលបានចុះបញ្ជីលើលិខិត ឯកសារ ស្លាកសញ្ញា ការផ្សាយព័ត៌មានរបស់ខ្លួន ដោយប្រើប្រាស់នាមករណ៍ជាភាសាខ្មែរដែលមានទំហំពីរដងធំជាងភាសាបរទេស។

**ប្រការ៨** .-

រាល់ការកែប្រែ ឬផ្លាស់ប្តូរម្ចាស់ស្ថាប័ន អង្គភាពសារព័ត៌មាន និងសោតទស្សន៍ ឬការផ្លាស់ប្តូរម៉ាក និងពាណិជ្ជនាមរបស់ស្ថាប័ន អង្គភាព រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើអាជីវកម្ម ឬសេវាកម្មក្នុងវិស័យព័ត៌មាន និង

សោតទស្សន៍ ត្រូវទទួលបានការអនុញ្ញាតពីក្រសួងព័ត៌មានជាមុនសិន មុននឹងធ្វើការចុះបញ្ជីកែប្រែនៅក្រសួងពាណិជ្ជកម្ម ។

**ប្រការ៩ .-**

ក្រសួងព័ត៌មានមានសមត្ថកិច្ចការពារផលប្រយោជន៍ និងការអនុវត្តសិទ្ធិរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលធ្វើអាជីវកម្ម ឬ សេវាកម្មកលើវិស័យព័ត៌មាន និងសោតទស្សន៍ នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៣
## កិច្ចការពារម៉ាក និងពាណិជ្ជនាមលើវិស័យព័ត៌មាន និងសោតទស្សន៍

**ប្រការ១០ .-**

សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក និងពាណិជ្ជនាមរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើអាជីវកម្ម ឬសេវាកម្មលើវិស័យព័ត៌មាន និងសោតទស្សន៍ ត្រូវបានទទួលស្គាល់តាមរយៈការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៤
## កម្រៃសេវាសាធារណៈ

**ប្រការ១១ .-**

កម្រៃសេវាសាធារណៈដែលទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម និងការចុះបញ្ជីម៉ាក និងពាណិជ្ជនាមលើវិស័យព័ត៌មាន និងសោតទស្សន៍ ត្រូវកំណត់ដោយឡែកនៅក្នុងប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម។

កម្រៃសេវាសាធារណៈសម្រាប់ការផ្តល់អាជ្ញាបណ្ណលើវិស័យសារព័ត៌មាន និងសោតទស្សន៍ ត្រូវអនុវត្តតាមប្រកាសរួមលេខ១០០៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងព័ត៌មាន។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**ប្រការ១២ .-**

រាល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានធ្វើអាជីវកម្ម ឬសេវាកម្មលើវិស័យព័ត៌មាន និងសោតទស្សន៍ ត្រូវស្នើសុំចុះបញ្ជីពាណិជ្ជកម្ម និងអាចស្នើសុំចុះបញ្ជីម៉ាកនិងពាណិជ្ជនាម នៅក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល ៦ (ប្រាំមួយ)ខែ

គិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ បើមានការចាំបាច់ ក្រសួងពាណិជ្ជកម្ម អាចសម្រេចបន្តរយៈពេលនេះបានចំនួន ៦ (ប្រាំមួយ) ខែ ទៀត។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ១៣ .-**

រាល់ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសអន្តរក្រសួង ស្តីពីការគ្រប់គ្រងការចុះបញ្ជីពាណិជ្ជកម្ម និងកិច្ចការពារម៉ាកនិងពាណិជ្ជនាមសម្រាប់អាជ្ញាបណ្ណលើវិស័យព័ត៌មាន និងសោតទស្សន៍នេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៤ .-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ នៃក្រសួងពាណិជ្ជកម្ម និងក្រសួងព័ត៌មាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១០កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ សីហា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

**ខៀវ កាញារីទ្ធ**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- អគ្គនាយកដ្ឋានពន្ធដារ
- ដូចប្រការ ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ